# សិលាចារឹកវត្តតាំងក្រសាំង ខេត្តកំពង់ធំ

វត្តតាំងក្រសាំង មានទីតាំងស្ថិតនៅភូមិតាំងក្រសាំង ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលមានចម្ងាយប្រមាណ ២៦ គីឡូម៉ែត្រ ប៉ែកនិរតីក្រុងស្ទឹងសែន។ វត្តតាំងក្រសាំង គឺជាអតីតទីតាំងប្រាសាទបុរាណកាលពីសម័យមុនអង្គរ (រវាងស.វ.ទី៧) តែក្រោយមកគេបានកសាងព្រះវិហារថ្មីមួយគ្របពីលើគ្រឹះប្រាសាទចាស់ ដែលនាំឱ្យបាត់រូបរាង និងស្លាកស្នាមទាំងស្រុង។ ទោះជាយ៉ាងនេះក្តី នៅមានវត្ថុសិល្បៈធ្វើអំពីថ្មភក់ជាច្រើន នៅសេសសល់ក្នុងបរិវេណវត្តនេះ។ គួរឱ្យចាប់អារម្មណ៍ មាននៅសល់សិលាចារឹកមួយផ្ទាំង ដែលសព្វថ្ងៃកំពុងតម្កល់ទុកនៅក្នុងសាលាឆាន់វត្តតាំងក្រសាំងផ្ទាល់តែម្តង។ តើសិលាចារឹកវត្តតាំងក្រសាំងមានខ្លឹមសារ និងអត្ថន័យដូចម្តេចខ្លះ?

សិលាចារឹកនេះ ជាប្រភេទចារឹកអក្សរនៅលើមេទ្វារប្រាសាទ មានចំនួន ១៤ បន្ទាត់ ជាភាសាសំស្ក្រឹត ហើយបើគិតជាស្លោកស្មើនឹង ៧ ស្លោក។ ក្នុងនោះ ផ្នែកខាងលើត្រូវបានរលុប និងត្រង់បាទទី៣ និងបាទទី៤ របស់ស្លោកទី៦ បានខូចខាតទាំងស្រុង និងមិនអាចអានបាន។

ចំពោះខ្លឹមសារជារួមរបស់សិលាចារឹកនេះ គឺស្លោកទី១ ពណ៌នាអំពីមហាសករាជឆ្នាំ៥៩០ ពេលព្រះចន្ទ្រ ស្ថិតនៅក្នុងរង្វង់នៃកន្យារាសី ៨រោច ថ្ងៃសុក្រ។ កាលបរិច្ឆេទនេះត្រូវនឹងគ.ស.ឆ្នាំ ៦៦៨ ពោល គឺត្រូវនឹងព្រឹត្តិការណ៍ក្នុងរជ្ជកាលព្រះបាទស្រីជយវម៌្ម (ទី១) (គ.ស.៦៥៧-៦៨១)។ ស្លោកទី២ ពណ៌នាអំពីការធ្វើអំណោយទាន។ ស្លោកទី៣ ពណ៌នាអំពីតង្វាយដល់ព្រះគ្រីមណ្ឌលេគ ពោល គឺសំដៅដល់ព្រះឥសូរនោះឯង។ **ព្រះគ្រីមណ្ឌលេគ** ទំនងជាមានទំនាក់ទំនងគ្នាជាមួយនឹងទេវស្ថានមួយទៀត ដែលមានទីតាំងស្ថិតនៅមិនឆ្ងាយប៉ុន្មានពីវត្តតាំងក្រសាំង។ ទីតាំងនោះគេស្គាល់ឈ្មោះបច្ចុប្បន្នថា "**ទួលសុពណ៌កាឡី**" ស្ថិតនៅភូមិប្រាសាទ ឃុំប្រាសាទ ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលទីនោះធ្លាប់រកឃើញសិលាចារឹកមួយផ្ទាំងចុះបញ្ជីលេខ K.1464 មានទេពព្រះនាម "**គ្រីមណ្ឌលេគ្វរ**" ហើយព្រះនាមនេះហើយដែលដូចទៅនឹងព្រះនាមទេពនៅសិលាចារឹកវត្តតាំងក្រសាំងនេះ។ ព្រះនាមទេពថា "គ្រីមណ្ឌលេគ" និង "គ្រីមណ្ឌលេគ្វរ" ជានាមតែមួយ ហើយក្នុងសិលាចារឹកវត្តតាំងក្រសាំងបានបង្ហាញថា ម្ចាស់តង្វាយទានបានបញ្ជាក់យ៉ាងជាក់លាក់ថាបានធ្វើអំណោយទានដល់ព្រះគ្រីមណ្ឌលេគ សំដៅដល់ព្រះគ្រីមណ្ឌលេគ្វរនោះឯង។ ចំណែកឯស្លោកទី៤ដល់ស្លោកទី៧ គឺជាពាក្យបណ្តាសា និងពរជ័យដល់ជនដែលបានបំផ្លាញ និងអ្នកដែលបានថែរក្សាទេវស្ថាន។

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់

## អត្ថបទចារឹក និងសេចក្តីប្រែ

១.　យស្មិញ្យាតេ គកបតៅ　　ខងវេមុកិរ៑ ..................
　　កុក្រោតជាម្ពមធិណោ　　សិតេកាញ្យាធិកគ្គតិះ។

ប្រែថា៖ *កាលឆ្នាំស្តេចសកកន្លងទៅហើយ កំណត់ដោយ ព្ស្ថម៉ុ=៥ នវ=៩ ខ=០ ...ព្រះចន្ទ្រ ជាដើមស្ថិតនៅក្នុងវង្វង់នៃកន្យារាសី ៨រោច ថ្ងៃសុក្រ។*

២.　ទ្វិចាងព្យោរ សុក្សេត្រ[មិ]　　ស វីជជម្មុភូមណះ
　　ជម្ងាថ៌ជម្ម៌កាកលោ　　ជម្នោជម្នោតិរាម្ពរះ

ប្រែថា៖ (*តង្វាយមាន*) *មនុស្សផង និងដីស្រែចម្ការដ៏ល្អផង មានបុរសម្នាក់ដែលស្រស់សោភាដោយពន្លកនៃព្រះធម៌ ជាបុគ្គលដែលប្រកបដោយកុសលធម៌ និងធម៌អាថ៌ ប្រៀបបីដូចជាពស្ត្រានៃព្រះធម៌ ។*

៣.　ច្រាជាដ្រ្វីមណ្ឌលេគាយ　　ទេវតិលាជិសាក្សិនិ
　　ស គីត្តិស្នេហាមិច្ឆន្តិ　　បុនជ្ជាំដ្ឋាន្តរេម្វបិ។

ប្រែថា៖ *បានថ្វាយហើយដល់ព្រះគ្រីមណ្ឌលេគ ឮដ៏ទេពសិលាជាដើមដែលជាកសិណសាក្សី ហើយគាត់បានប្រាថ្នាដើម្បីជួបស្នេហ៍ និងកិត្យានុភាព សូម្បីក្នុងជន្មាន្តរៈទាំងឡាយនានាទៀត។*

៤.　អត៌មិច្ឆន្តិគោក្សេត្រំ　　ចាបិម្ពាះចាបវ្ឫទ្ធយះ
　　អវីចីនរកំយោរមិ　　បច្ឆន្តេបិត្ឫភិស្សហ។

ប្រែថា៖ *ពួកជនមានចិត្តបាប ជាបុគ្គលចម្រើនដោយបាប ប្រាថ្នាបំផ្លាញនូវស្រែចម្ការ និងគោ នឹងត្រូវគេចម្អិនយ៉ាងឃោរឃៅក្នុងនរក ព្រមទាំងញាតិទាំងឡាយមានឪពុកជាអាទិ៍។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

៥.  កល្បកោដិសហស្រានិ  កល្បកោដិ[ដ្យ?]យុតានិ ច
អវីចីនរកំឃោរមិ  បច្យន្តេបិចតុយ៌្យុ[គេ]។

ប្រែថា៖ *អស់រយៈពេលរាប់ពាន់កោដិនៃកប្បផង អស់រយៈពេលរាប់ម៉ឺនកោដិនៃកប្បផង នឹងត្រូវគេចម្អិនយ៉ាងឃោរឃៅក្នុងនរក សូម្បីឮដ៏យុគទាំង៤។*

៦.  ស្វទត្តាំបរទត្តាំវា  យោហរេត្តវសុន្ធរា
........................  ......................។

ប្រែថា៖ *ទ្រព្យសម្បត្តិក្នុងដែនដីនេះដែលត្រូវបានបូជាថ្វាយហើយ ដោយខ្លួនឯងក្តី ឬដោយជនដទៃក្តី ជនណាលួចយកទៅ ......................។*

៧.  បម្ពីវម៌សហស្រា[ណិ]  ស្វត៌្តមាជីតិភូ[មិមុ]
អាច្ឆេត្តា ចានុមន្តា ច  តាន្យេវ នរកេ វសេត៍។

ប្រែថា៖ *រយៈពេលប្រាំមួយម៉ឺនឆ្នាំ គប្បី(រស់នៅ)ឮដ៏ស្ថានសួគ៌ជាដើម។ រីឯពួកអ្នកបំផ្លិចបំផ្លាញក្តី ពួកអ្នកចូលដៃជាមួយក្តី ក៏គប្បីរស់នៅក្នុងនរកអស់រយៈកាលប៉ុណ្ណោះដូចគ្នា។*

*សរុបជារួមមក សិលាចារឹករកឃើញនៅវត្តតាំងក្រសាំង រៀបរាប់អំពីការធ្វើកុសលផលបុណ្យរបស់ម្ចាស់ទានម្នាក់ថ្វាយចំពោះទេពមួយអង្គព្រះនាម "គ្រីមណ្ឌលេឝ" (ព្រះឥសូរ)។ ដូច្នេះទិន្នន័យនេះ បានបង្ហាញឱ្យឃើញអំពីការគោរពប្រណិប័តន៍ព្រហ្មញ្ញសាសនានិកាយសៃវ យ៉ាងជ្រាលជ្រៅនៅស.វ.ទី៧ ក្នុងរជ្ជកាលព្រះបាទស្រីជយវម៌្មទី១ (គ.ស.៦៥៧-៦៨១) ដ្បិតមានសិលាចារឹកជាច្រើនក្នុងរាជ្យរបស់ទ្រង់ដែលពណ៌នាអំពីការគោរពបូជាចំពោះព្រះឥសូរ។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*



រូបលេខ១៖ ព្រះវិហារថ្មីវត្តតាំងក្រសាំង សង់នៅលើគ្រឹះប្រាសាទស.វ.ទី៧

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ កំ វណ្ណាក់ និងព្រះតេជគុណ អេង សុគង់



រូបលេខ២៖ សំណៅផ្តិតសិលាចារឹកវត្តតាំងក្រសាំង (ផ្តិតដោយ៖ កំ វណ្ណារ៉ា និង ម៉ង់ វ៉ាលី)

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់